ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL

ក្រុងគ្រីស្ទានសាន់ (ន័រវេស៍) ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០

# សេចក្តីថ្លែងការណ៍
# រដ្ឋាភិបាលកម្ពុជាដោះលែងលោក រ៉ុង ឈុន ជាបន្ទាន់

ដោយកត់សម្គាល់ឃើញថា រដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បន្តដើរផ្ទុយពីគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងប្រាសចាកពីខ្លឹមសាររដ្ឋធម្មនុញ្ញទាំងស្រុង ដែលជំនួសដោយការដឹកនាំតាមយន្តការអន់ថយ និងផ្តាច់ការជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ បំបិទសិទ្ធិបញ្ចេញមតិ **ជាពិសេសបង្ក្រាបលើសកម្មជនសហជីព ខណៈដែលប្រព័ន្ធអនុគ្រោះពន្ធ EBA របស់សហភាពអឺរ៉ុប ខិតជិតដល់កាលកំណត់ឱសានវាទ «ផ្តាច់ ឬបន្ត EBA» នៅថ្ងៃទី១២ ខែសីហា ខាងមុខនេះផង និងចំពេលដែលស្ថានភាពព្រំដែនកម្ពុជា ត្រូវបានប្រទេសវៀតណាម ចូលបោះតង់ កើនឡើងចំនួន ២៨៤ តង់ នៅតាមបណ្តោយព្រំដែនដែលជាការគំរាមកំហែង និងរំលោភឈ្លានពាន មកលើបូរណភាពទឹកដីកម្ពុជា។**

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមថ្កោលទោសយ៉ាងដាច់អហង្កា ចំពោះអាជ្ញាធររដ្ឋាភិបាលកម្ពុជា ចាប់ខ្លួន **លោក រ៉ុង ឈុន តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និងជាប្រធានសហភាពសហជីពកម្ពុជា** ក្រោមបទចោទប្រកាន់អំពី*«ការបំភ្លៃពិតលើបញ្ហាព្រំដែន ជាបទល្មើសជាក់ស្តែង តាមមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ»* កាលពីម៉ោង ៩:៤០ នាទី នៅរាត្រីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២០។ **ករណីការចាប់ខ្លួននេះ មិនមែនជាបទល្មើសជាក់ស្តែងដូចការចោទប្រកាន់ឡើយ ប៉ុន្តែជារឿងនយោបាយ និងជាការធ្វើឡើងខុសម៉ោងរដ្ឋបាល** ហើយនិងធ្វើទៅតាមទំនើងចិត្តរបស់អាជ្ញាធររដ្ឋាភិបាល ដែលរំលោភយ៉ាងធ្ងន់ធ្ងរលើរដ្ឋធម្មមនុញ្ញកម្ពុជា ជំពូកទី៣ ស្តីអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ត្រង់កថាខណ្ឌទី១ នៃមាត្រា៤១ ព្រមទាំងរំលោភលើមាត្រា១៩ នៃសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស។

**លោក រ៉ុង ឈុន** គឺសកម្មជនសហជីព និងសកម្មជនព្រំដែនដ៏ឆ្នើម ដែលចូលរួមជាមួយបងប្អូនកម្មករ ក្រុមគ្រូបង្រៀន ពលរដ្ឋរងគ្រោះដីធ្លី ដើម្បីយុត្តិធម៌សង្គម និងបានចុះអង្កេតសកម្មភាពរំលោភព្រំដែនកម្ពុជា ពីសំណាក់ប្រទេសវៀតណាម ពេលថ្មីៗនេះ។ ជាក់ស្តែងនៅក្នុងសេចក្តីថ្លែងការណ៍ក្នុងនាមជា**តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** កាលពីថ្ងៃទី២១ ខែកក្កដាកន្លងទៅ **លោក រ៉ុង ឈុន** បានធ្វើឡើងដោយផ្អែកលើការចុះអង្កេតផ្ទាល់ ឃើញជាក់ស្តែងថា ***«ការបោះបង្គោលព្រំដែន លេខ ១១៤ ដល់លេខ ១១៩ មានភាពមិនប្រក្រតីច្រើន ដែលធ្វើឲ្យពលរដ្ឋបាត់បង់ដី ទៅភាគីវៀតណាមជាច្រើនរយហិកតា»*** នៅឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ដែលជាដីដូនតាកសិករខ្មែរ។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមអំពាវដល់រដ្ឋាភិបាល និងតុលាការកម្ពុជា ដោះលែងលោក **រ៉ុង ឈុន** ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ ដើម្បីរួមចំណែកលើកកម្ពស់សិទ្ធិមនុស្សឡើងវិញ សិទ្ធិបញ្ចេញមតិ សិទ្ធិជួបប្រជុំជាសាធារណៈរបស់ពលរដ្ឋ និងសហជីពកម្មករ ព្រមទាំងរួបរួមគ្នាការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដីខ្មែរ ស្របតាមខ្លឹមសាររដ្ឋធម្មនុញ្ញកម្ពុជា គោលការណ៍ច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១។

**ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ម៉ែន ណាត**

Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Contact nathamonin@gmail.com /
Hompage: https://cwcicambodia.net